THE SCHOOL DISTRICT OF PHILADELPHIA

របាយការណ៍វឌ្ឍនភាពរបស់សាលារៀនស្តីពីការអប់រំ និងសមធម៌ (School Progress Report on Educationand Equity (SPREE))

ទិដ្ឋភាពទូទៅសម្រាប់ក្រួសារសិស្ស

SPREE និងគោលដៅ & វិធានការតម្រង់[1] របស់ក្រុមប្រឹក្សាអប់រំ

THE SCHOOL DISTRICT OF PHILADELPHIA BOARD OF EDUCATION

GOALS & GUARDRAILS

នៅខែធ្នូ ឆ្នាំ 2020 ក្រុមប្រឹក្សាអប់រំ (Board of Education (BOE)) បានរៀបចំឡើងនូវគោលដៅ & វិធានការតម្រង់ ដែលកំណត់អាទិភាពច្បាស់លាស់លើចំណេះដឹងដែលសិស្សត្រូវចេះ និងលទ្ធផលដែលសិស្សមានសមត្ថភាពសម្រេចបាន និងដែលបរិយាយពីលក្ខខណ្ឌផ្សេងៗ ដែលត្រូវតែដាក់ចេញនៅតាមសាលារៀននីមួយៗ ដើម្បី ផ្តល់លទ្ធភាពដល់សិស្សរបស់យើងសម្រេចជោគជ័យក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន។

មណ្ឌលសាលាបានដាក់ចេញនូវមុខញ្ជាញ 5 ឆ្នាំ ដែលសាលារៀនត្រូវសម្រេចឲ្យបាន ដើម្បីបង្ហាញថា សាលារៀនកំពុងមានភាពវិកចម្រើនឆ្ពោះទៅសម្រេចគោលដៅ & វិធានការតម្រង់នោះ។ របាយការណ៍វឌ្ឍនភាពរបស់សាលារៀនស្តីពីការអប់រំ និងសមធម៌ (SPREE) គឺជារង្វាស់សំខាន់បំផុតមួយ ដែលបង្ហាញពីវឌ្ឍនភាពរបស់សាលារៀននីមួយៗ ឆ្ពោះទៅសម្រេចមុខញ្ជាញប្រចាំឆ្នាំ និងលទ្ធផលរបស់ខ្លួនលើរង្វាស់សំខាន់ៗផ្សេងទៀត ដូចជា អត្រាវត្តមាន និងអត្រាបញ្ចប់ការសិក្សា។

ឯកសារមគ្គុទេសក៍នេះ នឹងជួយឲ្យអ្នកយល់ដឹងអំពីរបាយការណ៍ SPREE សម្រាប់សាលារៀនរបស់កូនអ្នក និងផ្តល់ជាដំបូន្ថានអំពីរបៀបដែលអ្នកអាចជួយឲ្យកូនរបស់អ្នកបានជោគជ័យ។

[1] សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ https://www.philasd.org/schoolboard/goals-and-guardrails/

តើ SPREE ជាអ្វី?

SPREE គឺជាផ្នែកនៃកិច្ចការរបស់មណ្ឌលសាលា ដើម្បីកែលម្អសាលារៀនរបស់យើងបន្តឥតឈប់។ របាយការណ៍ SPREE ត្រូវបានចេញផ្សាយរៀងរាល់ឆ្នាំ និងផ្តល់នូវសេចក្តីសង្ខេបអំពី ថាតើសាលារៀននីមួយៗបានអនុវត្ត និងកែលម្អ យ៉ាងដូចម្តេច ផ្អែកលើគោលដៅ & វិធានការតម្រង់ និងវង្វាស់សំខាន់ៗផ្សេងទៀត ក្នុងចំណុចដូចខាងក្រោម៖

- **អំណាន & ជំនាញភាសាអង់គ្លេស English Language Arts (ELA)**
- **គណិតវិទ្យា & វិទ្យាសាស្ត្រ**
- **ការត្រៀមលក្ខណៈសម្រាប់មហាវិទ្យាល័យ & អាជីព**
- **បរិយាកាសវប្បធម៌ & ឱកាស**

វដ្តកែលម្អប្រចាំឆ្នាំលើគោលដៅ & វិធានការតម្រង់

SPREE របស់ខ្លួន ដើម្បីបង្កើតផែនការកែលម្អសម្រាប់ឆ្នាំបន្ទាប់ ដើម្បីជួយឲ្យសិស្សបានជោគជ័យ និងមានវឌ្ឍនភាពឆ្ពោះទៅសម្រេចនូវគោលដៅ និងវិធានការតម្រង់ ឲ្យបានល្អប្រសើរឡើង។

1 ការពិនិត្យវឌ្ឍនភាពនៅមណ្ឌលសាលា

ត្រួតពិនិត្យជាប្រចាំពេញមួយឆ្នាំ ដើម្បីតាមដានវឌ្ឍនភាពរបស់មណ្ឌលសាលាឆ្ពោះទៅសម្រេចគោលដៅ & វិធានការតម្រង់ និងពិចារណាលើយុទ្ធសាស្ត្រកែលម្អ។

2 របាយការណ៍វឌ្ឍនភាពរបស់សាលារៀន (SPREE)

សេចក្តីសង្ខេបប្រចាំឆ្នាំអំពីវឌ្ឍនភាពរបស់សាលារៀននីមួយៗ ឆ្ពោះទៅសម្រេចគោលដៅ & វិធានការតម្រង់ និងវង្វាស់សំខាន់ៗផ្សេងទៀត។

3 ផែនការកែលម្អសាលារៀន

ប្រើប្រាស់លទ្ធផល SPREE ដើម្បីដាក់ចេញនូវគោលដៅ និងវិធានការតម្រង់ និងកំណត់យុទ្ធសាស្ត្រនៅសាលារៀន ដើម្បីជួយដល់ការកែលម្អ។

4 ការពិនិត្យវឌ្ឍនភាពនៅសាលារៀន

ត្រួតពិនិត្យជាប្រចាំពេញមួយឆ្នាំ ដើម្បីតាមដានភាពរីកចម្រើន និងវឌ្ឍនភាពរបស់សាលារៀននីមួយៗ ឆ្ពោះទៅ សម្រេចគោលដៅរបស់ខ្លួន។

យល់ដឹងពីកម្រិតថ្នាក់ SPREE របស់អ្នក

មានវង្វាស់ផ្សេងៗគ្នាពី 10 ទៅ 13 ដែលត្រូវបានវាយតម្លៃក្នុងរបាយការណ៍ SPREE។ **ចំពោះវង្វាស់នីមួយៗ** របាយការណ៍ SPREE របស់សាលារៀនអ្នក ផ្តល់ជូននូវព័ត៌មានចំនួនពីរ។ ព័ត៌មានទី 1 គឺ របាយការណ៍ប្រាប់យើងថាតើ សាលារៀនកំពុងសម្រេចនូវមុខព្រួញប្រចាំឆ្នាំសម្រាប់វង្វាស់នោះ ឬយ៉ាងណា? ព័ត៌មានទី 2 គឺ របាយការណ៍ប្រាប់យើងថាតើ សាលារៀនបានរីកចម្រើនត្រង់វង្វាស់នោះ ប្រសើរជាងឆ្នាំមុន ឬយ៉ាងណា?

ផ្អែកលើព័ត៌មាននោះ វង្វាស់នីមួយៗ ត្រូវបានកំណត់ព៌ណមួយ៖

កំពុងសម្រេច & កំពុងរីកចម្រើន៖ សាលារៀនបានសម្រេចនូវការរំពឹងទុកសម្រាប់ឆ្នាំសិក្សានោះ និងបានរីកចម្រើនប្រសើរជាងឆ្នាំមុន។

កំពុងសម្រេច & មិនរីកចម្រើន៖ សាលារៀនបានសម្រេចនូវការរំពឹងទុកសម្រាប់ឆ្នាំសិក្សានោះ ប៉ុន្តែមិនបានរីកចម្រើនប្រសើរជាងឆ្នាំមុន។

មិនសម្រេច & កំពុងរីកចម្រើន៖ សាលារៀនមិនសម្រេចនូវការរំពឹងទុកសម្រាប់ឆ្នាំសិក្សានោះ ប៉ុន្តែបានរីកចម្រើន ប្រសើរជាងឆ្នាំមុន។

មិនសម្រេច & មិនរីកចម្រើន៖ សាលារៀនមិនសម្រេចនូវការរំពឹងទុកសម្រាប់ឆ្នាំសិក្សានោះ ហើយក៏មិនរីកចម្រើន ប្រសើរជាងឆ្នាំមុនដែរ។

SPREE នឹងផ្តល់កម្រិតថ្នាក់រួមមួយសម្រាប់សាលារៀននីមួយៗ -- លទ្ធផលរួមនៃការអនុវត្ត និងការកែលម្អទៅលើមុខព្រួញ ឬវង្វាស់នីមួយៗ។ កម្រិតថ្នាក់រួមនោះ នឹងជាកម្រិតថ្នាក់មួយ ក្នុងចំណោមកម្រិតថ្នាក់ទាំងនេះ។

កម្រិតថ្នាក់ទី 1

- សម្រេចបាននូវមុខព្រួញ នៃការអនុវត្តភាគច្រើន ឬទាំងអស់
- កែលម្អលើមុខព្រួញ ឬវង្វាស់ បានយ៉ាងតឹងតាក់តណ្តឹល

កម្រិតថ្នាក់ទី 2

- សម្រេចបាននូវមុខព្រួញ នៃការអនុវត្តភាគច្រើន ឬទាំងអស់
- ការកែលម្អស្ថិតនៅអត្រាថេរ ឬធ្លាក់ចុះ

កម្រិតថ្នាក់ទី 3

- សម្រេចបាននូវមុខព្រួញ នៃការអនុវត្តខ្លះ
- កែលម្អលើមុខព្រួញ ឬវង្វាស់ បានយ៉ាងតឹងតាក់តណ្តឹល

កម្រិតថ្នាក់ទី 4

- សម្រេចបាននូវមុខព្រួញ នៃការអនុវត្តខ្លះ
- ការកែលម្អស្ថិតនៅអត្រាថេរ ឬធ្លាក់ចុះ

កម្រិតថ្នាក់ទី 5

- មិនសម្រេចបាននូវមុខព្រួញ នៃការអនុវត្ត
- កែលម្អលើមុខព្រួញ ឬវង្វាស់ បានយ៉ាងតឹងតាក់តណ្តឹល

កម្រិតថ្នាក់ទី 6

- មិនសម្រេចបាននូវមុខព្រួញ នៃការអនុវត្ត
- ការកែលម្អស្ថិតនៅអត្រាថេរ ឬធ្លាក់ចុះ

តើអ្នកអាចជួយបានដោយរបៀបណា?

- **ជជែកជាមួយកូនរបស់អ្នកអំពីសារៈសំខាន់ និងសេចក្តីសប្បាយពីការសិក្សារៀនសូត្រ** ដើម្បីលើកទឹកចិត្តឲ្យគាត់មានវត្តមានទៀងទាត់ -- ត្រូវប្រាកដថា គាត់មិនត្រូវអវត្តមានលើសពីប្រាំបី (8) ថ្ងៃ ក្នុងឆ្នាំសិក្សានីមួយៗឡើយ។
- **យល់ដឹងពីកាលវិភាគប្រចាំថ្ងៃរបស់កូនអ្នក និងថ្ងៃប្រឡង។** ត្រូវប្រាកដថា កូនរបស់អ្នកបានសម្រាក និងត្រៀមខ្លួន ហើយលើកទឹកចិត្តគាត់ឲ្យខិតខំប្រឹងប្រែងជានិច្ច។
- **តាមដានសៀវភៅសិក្ខាការិក និងលទ្ធផលប្រឡងរបស់កូនអ្នក** ក្នុងអំឡុងឆ្នាំសិក្សា។ ធ្វើការអត់ធ្មត់ជាមួយពួកគេ ដើម្បីស្វែងរកឱកាសកែលម្អ ត្រង់ចំណុចដែលចាំបាច់។
- **ពិភាក្សា និងរំឭកមេរៀន**ជាមួយកូនរបស់អ្នក ដើម្បីជួយគាត់ឲ្យចងចាំមេរៀន ដែលពួកគេបានរៀនរួចហើយ។
- **ចូលរួមកែលម្អសាលារៀន តាមរយៈការឆ្លើយសំណួរក្នុងការស្ទង់មតិទូទាំងមណ្ឌលសាលា** រៀងរាល់និទាឃរដូវ (Spring)។ ផ្តល់មតិយោបល់ឥតលាក់លៀមអំពីសាលារៀន និងការអប់រំរបស់កូនអ្នក ហើយលើកទឹកចិត្តកូនរបស់អ្នកឲ្យធ្វើដូចគ្នាដែរ។
- **ធ្វើការជាមួយក្រុមប្រឹក្សាសាលារៀន (SAC) របស់អ្នក** ដើម្បីជួយកែលម្អរបៀបរៀន និងសមិទ្ធិផលសាលារៀនរបស់អ្នក។
- **ចុះឈ្មោះកូនរបស់អ្នកក្នុងកម្មវិធីរដូវក្តៅ ឬកម្មវិធីរកក្រើតឡើងវិញ ប្រសិនបើចាំបាច់** ដើម្បីផ្តល់ឱកាសឲ្យគាត់តាមទាន់ការសិក្សា។

THE SCHOOL DISTRICT OF PHILADELPHIA

របាយការណ៍វឌ្ឍនភាពរបស់សាលារៀនស្តីពីការអប់រំ និងសមធម៌ (SPREE)
ទិដ្ឋភាពទូទៅសម្រាប់គ្រួសារសិស្ស

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖ **www.philasd.org/spree**